ភ្នំពេញ ថ្ងៃទី១៩ ខែ មេសា ឆ្នាំ ២០១៦

ឯកឧត្តម ស៊ិនហ្សូ អាបេ
នាយករដ្ឋមន្ត្រីជប៉ុន
តូក្យូ

ឯកឧត្តម

ខ្ញុំមានសេចក្តីក្រៀមក្រំយ៉ាងខ្លាំង ដោយបានទទួលព័ត៌មានអំពីការបាត់បង់ជីវិតមនុស្សរាប់សិបនាក់ របួសជាច្រើន ព្រមទាំងការខូចខាតទ្រព្យសម្បត្តិយ៉ាងធ្ងន់ធ្ងរ ដែលបណ្តាលមកពីការរញ្ជួយដីយ៉ាងខ្លាំងជាប់ៗគ្នា ចាប់ពីថ្ងៃទី ១៤ មេសា មក នៅខេត្តគុម៉ាម៉ូតូ (Kumamoto) ភាគនិរតីនៃប្រទេសជប៉ុន ។

តាងនាមរាជរដ្ឋាភិបាល និងប្រជាជនកម្ពុជា ខ្ញុំសូមសំដែងនូវសមានចិត្តយ៉ាងជ្រាលជ្រៅ និងសូមចូលរួមរំលែកទុក្ខយ៉ាងក្រៀមក្រំ ជូនចំពោះឯកឧត្តម និងប្រជាជនជប៉ុន ជាពិសេសជនរងគ្រោះ និងសមាជិកក្រុមគ្រួសារអ្នកស្លាប់ ចំពោះការបាត់បង់ដ៏សោកសង្រេង និងសេចក្តីឈឺចាប់ដ៏ធំធេង ដែលបង្កឡើងដោយគ្រោះមហន្តរាយធម្មជាតិនេះ។

សូម ឯកឧត្តម ទទួលនូវការគោរពរាប់អានដ៏ខ្ពង់ខ្ពស់ពីខ្ញុំ ។

ហ៊ុន សែន